មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស
CENTER FOR ALLIANCE OF LABOR AND HUMAN RIGHTS-CENTRAL
ផ្ទះលេខ ៣៥៩ ផ្លូវលេខ ៦៩BT #359 Street 69BT Sangkat Boeung Tompun , Khan Meanchey, Phnom Penh
Tel: (855) 93 556 603 Email: info@central-cambodia.org Web: www.central-cambodia.org

# សេចក្តីថ្លែងការណ៍

## ពលរដ្ឋកម្ពុជាបន្តចាញ់បោកមេខ្យល់ដែលសន្យានាំទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង

ភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥

---

ពលរដ្ឋកម្ពុជាមួយចំនួននៅតែបន្តចាញ់បោកមេខ្យល់ ផ្សព្វផ្សាយ ប្រើល្បិចកុហកលួងលោមអូសទាញ ដោយសន្យាថា នាំទៅធ្វើការនៅបរទេសដែលមាន ការងារល្អ និងមានប្រាក់ឈ្នួលខ្ពស់។ ជាក់ស្តែងកាលពី ***ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៥*** កន្លងទៅនេះមានពលរដ្ឋកម្ពុជា ជាជនរងគ្រោះមកពីខេត្តផ្សេងៗគ្នាដូចជា៖ ព្រៃវែង តាកែវ កំពត កណ្តាល ស្វាយរៀង ព្រះវិហារ កំពង់ចាម ក្រចេះ កំពង់ឆ្នាំង បាត់ដំបង និងរាជធានីភ្នំពេញ បានមានបំណងចំណាកស្រុកទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ចំនួន **៤៨នាក់** ក្នុងចំណោមជនរងគ្រោះប្រមាណ**៣០០នាក់**ផ្សេងទៀត បានមករាយការណ៍ និងស្នើសុំជំនួយគាំទ្រពីអង្គការសង់ត្រាល់។ ពួកគាត់អះអាងថា “ *បានចាញ់បោកមេខ្យល់ដែលបានឃោសនាផ្សព្វផ្សាយជានាថាជួយស្វែងរកការងារឱ្យធ្វើនៅប្រទេសកូរ៉េខាងត្បូងដែលនឹងទទួលបានប្រាក់ឈ្នួលខ្ពស់ប្រមាណ* ***១០០ដុល្លារសហរដ្ឋអាមេរិក*** *ក្នុងមួយថ្ងៃ*”។

នាអំឡុង ***ខែកក្កដា ឆ្នាំ២០២៣*** ក្រុមមេខ្យល់ និងបក្សពួកបានផ្សព្វផ្សាយ និងឡាយតាម បណ្តាញសង្គមហ្វេសប៊ុកដោយអះអាងថា “ *ពួកគេមានក្រុមហ៊ុន សម្រាប់ផ្តល់សេវាស្វែងរកការងារធ្វើនៅប្រទេសកូរ៉េខាងត្បូង ជូនពលរដ្ឋកម្ពុជា ដែលមានបំណងចំណាកស្រុកទៅរកការងារធ្វើ*” ។ ក្រុមមេខ្យល់ និងបក្សពួកទាំងនោះបញ្ជាក់ថា“ *អ្នកដាក់ពាក្យទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ត្រូវបង់ប្រាក់ក្នុងម្នាក់* ***៤,០០០$ (បួនពាន់ដុល្លាសហរដ្ឋអាមេរិក)*** *សម្រាប់ថ្លៃរត់ការទាំងអស់ តែត្រូវបង់មុននៅពេលដាក់ពាក្យចំនួន* ***២,០០០$ (ពីរពាន់ដុល្លាសហរដ្ឋអាមេរិក)*** *និង* ***២,០០០$ (ពីរពាន់ដុល្លាសហរដ្ឋអាមេរិក)*** *ទៀតនឹងត្រូវបង់នៅពេលបានទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង*” *ពួកគេសន្យាថា* “ *នឹងសងប្រាក់វិញ ប្រសិនបើមិនបានទៅធ្វើការនៅប្រទេសកូរ៉េក្នុងរយៈពេល៣ខែបន្ទាប់ពីបង់ប្រាក់ និងចុះកិច្ចសន្យា*” ។

ដូច្នេះជនរងគ្រោះទាំងអស់បានទៅជួបមេខ្យល់នៅ ទីតាំងផ្ទះល្វែងមួយកន្លែងនៅរាជធានីភ្នំពេញ ហើយបានព្រមព្រៀង និងធ្វើកិច្ចសន្យា(តែជនរងគ្រោះភាគច្រើនមិនទទួលបានកិច្ចសន្យាមក រក្សា ទុកឡើយ)។ ជនរងគ្រោះទាំងអស់បានបង់ប្រាក់គ្រប់ៗគ្នាទៅឱ្យមេខ្យល់ ដោយផ្ញើរតាមរយៈគណនេយ្យ

ធនាគារ។ ទឹកប្រាក់ដែលជនរងគ្រោះទាំង **៤៨នាក់** បានបង់ទៅឱ្យមេខ្យល់ និងបក្សពួករបស់ពួកគេ មានចំនួនជាង **២៣ម៉ឺនដុល្លារសហរដ្ឋអាមេរិក**។

ផ្អែកតាមការស៊ើបអង្កេតរបស់អង្គការសង់ត្រាល់ មានជនរងគ្រោះសរុបទាំងអស់ **៣០០នាក់** បានចាញ់បោកមេខ្យល់អស់ទំហំទឹកប្រាក់ប្រមាណ **៧៥ម៉ឺនដុល្លារសហរដ្ឋអាមេរិក**។តែរហូតមកដល់ បច្ចុប្បន្ន ពួកគាត់មិនបានទៅធ្វើការនៅប្រទេសកូរ៉េដូចការសន្យាទេ ហើយក៏មិនទទួលបានប្រាក់សំណងត្រឡប់មកវិញដែរ។

ជនរងគ្រោះទាំងអស់កំពុងជួបការលំបាកជាខ្លាំង ដោយត្រូវបង់សងបំណុលដែលខ្ចីមកបង់ឱ្យទៅមេខ្យល់នោះ ខ្លះធ្លាក់ខ្លួនឈឺរាំរៃរហូតបាត់បង់អាយុជីវិត ខ្លះទៀតលក់ផ្ទះសម្បែង និងខ្លះរត់ចោលស្រុកកំណើតព្រាត់ប្រាស់គ្រួសារដើម្បីរកប្រាក់សងបំណុល និងរាប់រងជីវភាពក្រុមគ្រួសារ។

សូមបញ្ជាក់ផងដែរថា ជនរងគ្រោះមួយចំនួន ក្នុងចំណោមជនរងគ្រោះទាំងអស់បានដាក់ពាក្យប្ដឹងទៅសាលាដំបូងខេត្តកំពត ហើយមេខ្យល់ម្នាក់ត្រូវបានចាប់ខ្លួនដាក់ពន្ធនាគាររហូតដល់សព្វថ្ងៃតែមេខ្លោង និងបក្សពួកផ្សេងទៀតមិនទាន់ចាប់ខ្លួនបាននៅឡើយ ហើយជនរងគ្រោះទាំងអស់ក៏មិនទាន់ទទួលបានសំណងត្រឡប់មកវិញនៅឡើយដែរ។

## ការស្នើសុំរបស់ជនរងគ្រោះ៖

- ស្នើសុំស្ថាប័នពាក់ព័ន្ធដូចជា តុលាការ ក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ច។ល។ ជួយដោះស្រាយ ស្វែងរកយុត្តិធម៌ និងផ្ដល់សំណងដល់យើងខ្ញុំដែលជាជនរងគ្រោះ។
- ស្នើសុំស្ថាប័នពាក់ព័ន្ធដូចជា តុលាការ ក្រសួងមហាផ្ទៃ និងអាជ្ញាធរមានសមត្ថកិច្ច។ល។ ជួយដោះស្រាយ និងពន្លឿនដំណើការនីតិវិធី ព្រោះយើងខ្ញុំដែលជាជនរងគ្រោះកំពុងជួបការលំបាកជាខ្លាំងពីមួយថ្ងៃទៅមួយថ្ងៃ ខ្វះខាតថវិការសម្រាប់ផ្គត់ផ្គង់អាហារហូបចុក ការរស់នៅប្រចាំថ្ងៃ ជាពិសេសត្រូវសងបំណុលជាប្រចាំ។
- ជាចុងក្រោយក៏សូមផ្ដាំផ្ញើទៅដល់បងប្អូនទាំងអស់ ដែលមានបំណងទៅធ្វើការនៅបរទេសសូមប្រុងប្រយ័ត្នឱ្យបានខ្ពស់ ដោយត្រូវឈ្វេងយល់ព័ត៌មានឱ្យបានត្រឹមត្រូវច្បាស់លាស់ចៀសវាង ចាញ់បោកក្រុមមេខ្យល់ទុច្ចរិត។

## សច់គ្រាល់សូមអំពាចនាចះ

ការចំណាកស្រុកទៅធ្វើការនៅបរទេសជាជម្រើស និងការស្វែងរក ឱកាសការងារមួយសម្រាប់ពលរដ្ឋកម្ពុជា ដើម្បីទទួលបានប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ សងបំណុល និងសន្សំសម្រាប់ដោះស្រាយបញ្ហានាពេលអនាគត។ ស្របពេលជាមួយគ្នានេះពលរដ្ឋកម្ពុជាដែលមាន បំណងចំណាកស្រុក ឬបានចំណាកស្រុកទៅធ្វើការនៅបរទេសមួយចំនួនបានជួបប្រទះបញ្ហាជាច្រើន ផងដែរនៅក្នុងដំណើរការនេះ បញ្ហាសំខាន់ៗរួមមាន៖

១). តម្លៃសេវាខ្ពស់ក្នុងការស្វែងរកការងារធ្វើនៅបរទេស
២). ចំណាយពេលយូរក្នុងការដំណើរការស្វែងរកការងារធ្វើនៅបរទេស
៣). ដំណើរការមានភាពស្មុគស្មាញ និងគ្មានព័ត៌មានគ្រប់ជ្រុងជ្រោយ
៤). ប្រឈមនឹងការចាញ់បោក ក្រុមឆ្លៀតឱកាសដែលជាមេខ្យល់ខុសច្បាប់

បញ្ហាទាំងនេះបានបង្កផលលំបាកជាច្រើនដល់ពលរដ្ឋកម្ពុជា ដែលមានបំណងចំណាកស្រុក ឬបានចំណាកស្រុកទៅធ្វើការនៅបរទេស ហើយវាក៏បានជំរុញឱ្យពលរដ្ឋកម្ពុជា មួយចំនួន ចំណាក ស្រុក ទៅធ្វើការនៅបរទេសដោយប្រថុយប្រថានមិនមានឯកសារគ្រប់គ្រាន់ ហើយខ្លះបានចាញ់ បោក ឧក្រិដ្ឋជនដែលជាមេខ្យល់ បានផ្សព្វផ្សាយអះអាងធានាថាជួយស្វែងរកការងារនៅបរទេស ជូនពលរដ្ឋកម្ពុជា ។

## អនុសាសន៍៖

- ស្ថាប័នពាក់ព័ន្ធរួមមាន៖ រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ត្រូវបង្កើនការផ្សព្វផ្សាយពីសិទ្ធិ ច្បាប់ គោលនយោបាយ និងព័ត៌មានគ្រប់ជ្រុងជ្រោយ អំពីការចំណាកស្រុកទៅធ្វើការនៅបរទេសដោយសុវត្ថិភាព។
- ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរ មានសមត្ថកិច្ច ដែលផ្តល់សេវាក្នុងដំណើការចំណាកស្រុកទៅ ធ្វើការនៅបរទេស គួរដោះស្រាយបញ្ហាប្រឈមសំខាន់ៗរបស់ពលករដូចជា៖ *តម្លៃសេវាខ្ពស់ ការចំណាយពេលយូរ ភាពស្មុគស្មាញនៃដំណើរការ និង ការចាញ់បោកមេខ្យល់ខុសច្បាប់។*
- ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តល់សេវាគាំទ្រផ្នែកច្បាប់ជំរុញឱ្យទទួលបានយុត្តិធម៌ និងការពារសិទ្ធិ ដល់ពលករចំណាកស្រុកដែលរងគ្រោះពីការឆបោកក្នុងដំណើរការជ្រើសរើស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម អំពើជួញដូរមនុស្ស និងការរំលោភបំពានគ្រប់រូបភាព។

- ស្ថាប័នពាក់ព័ន្ធរួមមាន៖ រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ត្រូវចូលរួមចំណែក ជំរុញផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបង្កើតមុខរបរក្នុងស្រុកដល់ប្រជាជនកម្ពុជា និងអតីតពលករចំណាកស្រុកដែលវិលត្រលប់មកមាតុភូមិវិញ។

---

***<u>ទំនាក់ទំនងព័ត៌មានបន្ថែម</u>៖***

***១. លោក យុន ថារ៉ូ***

*ប្រធានគ្រប់គ្រងផ្នែកកម្មវិធី នៃអង្គការសង់ត្រាល់*

*ទូរស័ព្ទលេខ៖ +៨៥៥ ៩៣ ៥៥៦ ៦៧១*

***២. លោក ឌី ថេហូយ៉ា***

*ប្រធានកម្មវិធីប្រឆាំងការជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ នៃអង្គការសង់ត្រាល់*

*ទូរស័ព្ទលេខ៖ +៨៥៥ ៩៣ ៥៥៦ ៦៣១*